# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

---

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូសុវណ្ណញាណ ស៊ួរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

---

## បញ្ជីរឿង

| | | ទំព័រ |
|---|---|---|
| **ផ្នែកអក្សរសាស្ត្រ** | | |
| លោក ហេង-ឃាំង | កំពូលស្នេហា (តម្រូវនឹងបច់) ..... | ៦០៣ |
| ហ្លួងនិពន្ធមន្ត្រីញ៉ុក-ថែម | រឿងអង្គរវត្ត ក្នុងសតវត្សរ៍ទី ១៦-១៧ (តមក) | ៦៣៦ |
| លោក ពុយ-ប៊ុនស៊ួរ | ឆកសហស្សរាត្រី ភាគទី ១២ (តមក) .. | ៦៤៩ |
| **ផ្នែកសាសនា** | | |
| លោកមហាប៊ុណ្ណ - សុម្ភាគ | ស័ពិជាតក (តមក) .......... | ៦៥៦ |
| លោកអាចារ្យ ខៀវ - ឆនុ | ពុទ្ធប្បវត្តិ (ភាគ ៣ តមក) ....... | ៦៦៤ |

---

# កំពូលស្នេហា

## លោកហេង-យ៉ាន់ រៀបរៀង

(តមកនឹងចប់)

---

ព្រឹកឡើងស្អែកដែលមោទ លោកគ្រូបញ្ចប់ប្រញាប់ស្លៀកពាក់ ទៅកាន់គេហដ្ឋានយាយចិនសិន លុះដល់ស្ពានម៉ែប្រសទីយ៍ ស្រាប់តែប្រទះនឹងវានហ្វូងធំនៅនោះ សុំទោសលោកគ្រូជាអនេកបរិយាយ រួចហើយចាញនៃសឲ្យរត្តិការគេទៅទៀត ក្រោយដែលបើកប្រាក់ខែឲ្យ ។ លោកគ្រូក៏ដើរមួយៗ ជូនខ្លួន ចំព្រោះដើរហោតដល់ផ្ទះក្បាលហួយកញ្ចុយសន ថ្ងៃស្រាហើយ បានឡើងដំបែកនិបរិលត្រឡប់មកសំណាក់វិញ រៀបចំសំលៀកបំពាក់ជាកញ្ចប់ហាបស្បែកមួយ រួចយកលុយថ្លៃផ្ទះឲ្យម្ចាស់ផ្ទះ ហើយសូមលាឈប់ជួលតែម្តង ។

ទោះបីតែម្នាក់ឯងក្នុងស្រុកគេ គតញាតសន្តានក៏គ្មានពីពាក គ្មានការភ្ញៀវត្រៀមទទឹបញ្ចប់ជីវិតដោយខ្លួនឯង លោកគ្រូញញឹមគិតគំ ជនិតព្យាយាមណា កប៉ាល់ម៉េចលមើលឃើញ ខ្សែកាលដំបងរៀល ។

ទើបកាត់សេចក្តីថា ជីវិតរបស់អាត្មាអញនេះ គឺនៅនឹងប្រាក់ជំរឿសរាល់ខែនេះ ប្រាក់នេះអស់វេលាណាជីវិតអាត្មាអញក៏សះបង់ឲ្យត្រឹមនោះដែរ រួចក៏សំឡឹងមើលក្រដាសប្រាក់នៅដៃ ដោយយកចិត្ត

ទុកដាក់ ប៉ុន្តែផុតក៏សើចហួសហេតុ ព្រោះព្រាក់នោះឆោលអោយ បន្តិច រើសយកមកទុកវិញ ។

ពេលថ្ងៃរសៀលគេឃ្លាតបន្តិចទៅហើយ លោកគ្រូពេទ្យក៏ទាញ ខាប់ស្បែកជើងចេញពីផ្ទះល្វែង ហើយបស់ផ្លែឈើដែលខ្លួនធ្លាប់ស៊ីរាល់តាំង ប៉ុន្មាន ដើរសំដៅទៅមុខ ពុំដឹងជាត្រូវទៅទីណា លោកគ្រូផុតសម្លឹង តែត្រូវបេះបុកផលអោយខ្លួនឯង ។

* *

## ឃងទី ១៦

## សុខសមសេចក្តីប្រាថ្នា

ថ្ងៃនេះ អាកាសប្រែប្រាកដជាតទំនេរ តក់ខ្លួនពាក់ព្រាណមុខញញឹម ក្រោយមានចិត្តសប្បាយរីករាយខុសធម្មតា ពីព្រោះនឹកស្មានថា លោកនោះណុចនេត្រមុខជាទីស្រឡាញ់ពុំខានឡើយ ទើបស្រុះស្រស់តាក់តែងខ្លួន ចេញទៅមុខផ្ទះដូចកេត សំគាល់ភាក់ក្រៅនឹងកាយ រួចអង្គុយគង់កៅអីចាំមើល ផ្លូវតាម បើនបន្តិចចំពេលត្រូវបានឃើញនាងមកពីចម្ងាយ ពាលបើកភ្នែក ឃ្លាទៅក៏ក្តួចខ្លួនលៃនឹងតក្ក លង់គង់គោចរឯណាទីមួយមិនបានគេពើ ផល់ផលពេះកាន់ចុះឡើងកាមផ្ទ ហេតុផលគក្កក់បន្ទូចរានិសើរតោលខ្ជី គន្ធីត្រូវហាមនេះរកលើមុខ ។

នៅចំនួនបួនដប់ថ្ងៃក្រោយណោះ អាចារ្យទីគីបានដណ្ដឹងស្រមករនៅជាមួយហើយ ព្រះហេតុដូច្នេះម្ដបបានថាអាចារ្យមិនសូវគិតស្មោះ មើលតែកំពុងអង្គុយចាំ លោកនឹកទៅឯណា បាត់ទៅវិញមួយរំពេច អាចារ្យមិនពេញចិត្តនឹងគូស្រឡាញ់ខ្ញុំម្នា បើមិនស្រឡាញ់ដូចម្ដេចក៏ចូលទៅដណ្ដឹង បណ្ដានេះតែខ្ញុំអាចារ្យឯងក៏ដោះសារមិនរួចដែរ ប្អូនតែប្រយ៉ាងនេះ ប្អូនយ៉ាងនោះនឹងយកជាការពុំបាន ដោយពិតនោះ អាចារ្យជាមនុស្សខុសគេខុសឯងក៏លក់គ្នា មានសេចក្ដីប៉ុនប៉ងមិនប្រាកដជាប់ប្រែប្រួល តាប់នេះតាប់នោះមិនត្រោះត្រង់ណា ប្អូនស្រឡាញ់ណាស់នេត្រស្មើនឹងលេប តែបាត់មុខយូរកើតតក់ក្រហល់សោប់សល់មិនសប្បាយ ប្អូនឃើញមុខនាងហើយខៀសឆ្ងាយមិនឲ្យក្ដួបក៏សឹងមាន ចិត្តនោះកន្ទុះ-រាដូចកន្ទ្រាលើសម្ដបម្ដុះ ដូចពាក្យលោកថា "ទៀកតាមខ្យល់ខ្ទល់តាមលេក" ។

បើដូច្នោះ ដូចម្ដេចក៏បញ្ចេញសុខគេអកងខ្ញុំប្អូន - ខនេះអាចារ្យបានបញ្ជាក់ក្នុងចិត្តដែរ ព្រោះពេលដែលដឹងថានាងមិនមកព្រោះយប់ហើយ ក៏បែរទៅនឹកដល់សោកក្រដៃលេបុនាឃើញក្នុងគៀមស្រា ហើយដោះសេចក្ដីដូច្នេះ:

" បើតាមពាក្យលោកសុភាតនោះ អាត្មាអញបានធ្វើឲ្យសោកក្រប្រែះឆ្ងាយដើមក្រុងដោយមិនដឹងខ្លួន គួរឲ្យអាសូរសោកក្រណាស់

នោះបុកកសៅស្រែទាញណុជនទ្រើលស់ហើយមើលទៅ ផល់មិនសម
នឹងសេចក្តីប្រាថ្នាកិរិយាដាក់ស្រែទៅ ដើម្បីជួតបំផុតញនូវសេចក្តីទុក្ខ
អស់រោះភ្ជាប់ព្រោះតែញាដាការាវាមិនពិត ព្រោះខុសតែម៉ាត់ឯងឯបាន
នាំអ្នកខ្វះបច្ចុប្បន្ននិងអនាគត ហើយឥឡូវនឹងខ្លួនមេតុគឺមិនប្រាប់គ្នាឲ្យដឹង ។
សោភ័ក្ត្រកំសត់ហើយ ខ្លួនខ្ញុំសព្វថ្ងៃនេះក្រោមទឹកនៅជាត្រីហាក់សពន-
ពេលណាស់ មានបំណាន់តែទឹកនៅបួស ដែលនេះក្រោមម្ជុលព្រះ
នេត្រ័យ តែហើយហេតុផលមានគុណការតែជាស់ហើយ គោរី
តែតបស្នងសគុណលោកកុំឲ្យលោកព្រះពុទ្ធ ដល់ណុជនទ្រើបាន
ខ្លួនមកកន្លែងជិតរបស់ខ្ញុំ នាំឲ្យខ្ញុំក្រលៃក្រឡេកនឹងចិត្តទាំងពេលនេះតែនេះ
ពេញឲ្យបាត់ពីទីនេះ ផលមកត្រីបាននាំផាសុមនុស្សសុខក៏មិនដឹងពិត ។
យ៉ាងណាតាមតែផលនាផលបុណ្យចុះ ។

រួចស្រាប់តែការាវាញញឹមតែម្នាក់ឯង ព្រោះនឹងឃើញផល់ណុជ-
នទ្រើមិនស្រួលខ្លួន រួចការាវាក្រោកប្រឹងតែបាំងនាំមក ហើយនឹងផល
សោភ័ក្ត្រក៏ចាក់បំពេញឲ្យទៅហៅ តែមិនឃើញសោភ័ក្ត្រ អ្នកបំរើនោះក៏មក
ប្រាប់ការាវាវិញ ការាវាក៏កើតទុក្ខពិតផល់រឿងនេះទៅ ។

ថ្ងៃកន្លងទៅជាលំដាប់ ហេតុផលការាវិញដែលគេត្រៀបចំ
ណាំតាហាំពីតាហាំនេះការាវាទីផណុជនទ្រើ ពួកការាវាបាននាំគ្នាចូល
ភ្ញៀវចាន់រៀបនាំនាំនជើមឈើម្លូរ ភ្ញៀវដែលនៅស្រុកឆ្ងាយ

គឺជាមេឃក្ដៅគ្មានផ្គរលាន់ពេលយប់ ចំណែកសាម៉ឿនចាំនៅតែរបួស មិនបានរំភើបរំជួលផល់ថ្ងៃដែលជិតដល់កំណត់នោះឡើយ ថែមទាំងខ្វល់ខ្វាយមិនសូវលេង តែនៅតែមកលេងគ្នាដដែល និយាយគ្នាលេងទៅវិញទៅមក ជួបបងប្អូនជានឹក, ថ្ងៃមួយមាតាប្រាប់ដំណឹងគួរឲ្យចង់មើល កើតមានចាប់ផ្ដាក់ទឹក សោកក្រៃផ្ទួ ទើបកូនសួរមាតាថា.-

“ប្អូនដែលឃើញសោកក្រៃផ្ទួ បងឲ្យគេទាយតាមព្រើនលើន ហើយមិនប្រទះទឹកសោះ” ។

“បងមានប្រសាសន៍ពីចិត្ត ជួបដាច់ស្រឡាញ់ បើសោកក្រៃណាស់នៅថ្ងៃមួយក៏បងនឹងកំណាត់កន្លងជួបម្ដងទៀត ?

កម្លាំងស្នេហ៍លោកដែលមានចិត្តស្រឡាញ់ប្រុសហើយ ទុកដាក់ចិត្តមិនចឹងជួបម្ដង ក៏ទាំងនៅក្រែងគេសង្ស័យផង ម្ល៉ោះហើយ ការនៅតែតូចទុកជាមុនជាប ។

“មិនជួបគ្នាទេប្អូន, បានជាបងសួរនោះកាលបើគ្មានសោកក្រៃ បងពាក់ដូចជាមិនសប្បាយ ព្រោះសោកក្រៃអាចនឹងក្បត់តែងមានរបៀបរៀបរយល្អ រូបភាពភ្លឺនៅហៅអ្នកបំរើម្ចាស់”

“តែឯងនៅទេសោកក្រៃមិនទៀតទេ ដើរឃើញម្យ៉ាងខ្សោយទេ” ។

"ដំណឹងប្រែសាសន៍ លោកគ្រូមិនដឹងជាទៅណាទេ អ្នកម្ចាស់ផ្ទះគេបានប្រាប់ខ្ញុំថាលោកគ្រូណាឈប់ជួលផ្ទះបន្ទប់រកចិត្តមកហើយ មិនដឹងជាសាត់ព្រាត់ទៅឯណាទេ" ។

នៅពេលនោះ អាចារ្យង៉ាក់មើលមុខណុជនេត្រ តែឆាន់បែរចេញដើរទៅរបងផ្កាកុឡាបទៅ អាចារ្យទើបពាត់ឲ្យអ្នកបំរើដើរតាមលោកគ្រូ ហើយឡើងទៅលើផ្ទះអង្គុយគិតថា

"លោកគ្រូដឹងជាក់ជាអញរៀបការនឹងណុជនេត្រ បានជាគៀសខ្លួនចេញពីក្រុងដោយឥតប្រាប់នរណាមួយម៉ាត់ ការណ៍នេះគោងតែអញរៀបចំឲ្យស្រួលបួលឡើង មួយវិញទៀត លុះដោយសេចក្តីកាប់ដោត លោកគ្រូច្បាស់ជាកំពុងស្រវឹងអែកគេងគៀមស្រាណាហើយ មើលទៅនេះបំជាស្រវឹងមែន ហើយអាចារ្យក៏អស់សំណើច" ។

តែលោកគ្រូអកមិនបានស្រវឹងដូចពាក្យអាចារ្យនោះទេ ព្រោះតាំងពីបានបរាជ័យនឹងណុជនេត្រវិញ លោកគ្រូលែងប្រព្រឹត្តសុរាទៀត ឈានជើងដើរតាមគន្លងដ៏ល្អទៀតវិញ នៅពេលដែលលោកគ្រូចេញចាកទីក្រុងទៅនោះ បានឡើងជិះកប៉ាល់មិនដឹងជាកប៉ាល់ណា ព្រោះលោកគ្រូមិនគិត ។

លុះស្លូតកប៉ាល់ឲ្យសំពួសញ្ញាបីដងហើយ ក្លិកម៉ាកំអៀស្រាយក្នុងយុថ្កា កប៉ាល់ក៏ចេញចាកផែ លោកគ្រូនឹកខ្លោចចិត្តស្រណោះម៉ឺ

កន្ទក់ក្ដាស់រវិលមួយជុំ គឺនាំខ្លួនសោកក្រៀមឲ្យឃ្លាតឆ្ងាយពីក្រមុំកំពែញទៅ
មន្ទិល ក៏ក្រុងដែលបានប្រដៅឲ្យសោកក្រោះស្រឡាញ់ ឥឡូវមកបាត់
ឆ្ងាយៗ ឆ្ងាយអើយសែនឆ្ងាយ លែកសាក់ចេញកាមជាយកបាល់ទៅទាន
ទៅចំរើនដើមនៃនិន្នាញ្ញែយរៀបៗ ផ្ទុជាតិកាមធ្មេះខេខ្មែរស្រស់ប៉ព្រៃនាវ
ស្ដេចពិតពីលម៉េលមើល តែសោកក្ដៅក្រះខ្សាចមើលទៅឃើញមុខ
ណុដនេក្រនាវដែលញញឹមយ៉ាងក្រៀមករេ ។

“ចិត្តលេងបារស់ស្រាញ់ទៅឆ្ងាយ ស្តីឲ្យចិត្តស្តាយណុងខ្លួនសួមី
ស្តីម៉ោះទេ” ។

“ឱចិត្តអើយចិត្ត អ្នកណាតែងយកពាក្យខ្ញុំទៅប្រាប់ដល់ម៉ាដឺផនី
ណុដនេក្រសំឡាញ់ចិត្តផងចងអើយ បងសូមលាប្អូនទៅឆ្ងាយហើយ
បងមុខជាមិនបានជួបមុខប្អូនទៀតទេ ប្អូនអើយ ខ្លួនបងសព្វថ្ងៃនេះ សែន
ពិតនាដល់អ្វីក្រៅពីប្អូន ដូចម្ដេចក៏មិនមេត្តាដល់ខ្ញុំផង ឲ្យខ្ញុំចិត្តឈ
មាឌណុដនេក្រផងខ្ញុំ ឲ្យក្រៀមក្រំជាទុក្ខព្រួយស្រាចស្រាក្ត ឲ្យរំភាខលេង
ក្រហាល់ក្រៀនក្រុលថ្ងៃ សមខ្ញុំខឹងក្ស័យជីវិតកើតមិនយូរប៉ុន្មាន ឲណុដ
នេក្រ សមនាងសះស្រែនសៅស្រីយ៉ាងណា ទៅដែលបងមិនបានទៅជិតប្អូន
តែម្ដេចក៏ម្ចាស់ផងយើង ឲម្ដេចប្អូនបានជួបណាក់ បងនេះ បើគេហៅ
ទៀតផល់ ចិត្តខ្ញុំប្រៀបគឺមិនចេះនិយាយ” ។

សោភ័ក្រ្តឈរមុខស្រៀមតែម្នាក់ឯង ស្រីរបៀនគបាំលរហូតដល់ យប់ស្រៀវព្រះចន្ទបុះផុតព្រៃបាំងបាត់រង្វង់ទៅ ទើបសោភ័ក្រ្តក្រាក់ខ្លួន ខ្សឹកខ្សួលឡើងថា " នុះព្រះចន្ទដែលបាំងបាត់ក្នុងដើមឈើ វិស័យ ដូចជីវិតរបស់គាគាអញហ្ន៎ " ។

យើងនឹងមិនអធិប្បាយឲ្យហួសហេតុពីដំណើរនោះទេ ព្រោះការនាំឲ្យ ធុញទ្រាន់ មួយវិញទៀតមិនសូវជាមានរឿងសំខាន់ដែរ ត្រៀមតែសេចក្ដី ថាកញ្ញូរបស់សោភ័ក្រ្តវង្វេងកល់ទិវារាត្រី យើងចាប់និយាយដល់សោ-ភ័ក្រ្តនៅកណ្ដាលផ្លូវគ្មានស្រុកមួយ ដែលមិនប្រាកដជាស្រុកអ្វី ព្រោះ សោភ័ក្រ្តមិនបានចាំឥតនា នេះគ្រាន់តែដើរដូចមនុស្សឥតវិញ្ញាណ ។

កាលបើដើរផ្លូវជាយូរថ្ងៃ អស់កំឡាំងហើយឃ្លានការពារផង សោ-ភ័ក្រ្តក៏ដេកដោនរំលងមុខអង្គុយលើចិញ្ចើមថ្នល់ ដួលសន្លប់បាត់ស្មារតីទៅ បន្តពេលនោះ មានឡានខ្លាតតូចមកដល់ទីនោះ អ្នកម្ចាស់ឡានក៏ស្ទុះ លើកសោភ័ក្រ្ត ឃើញមុខហើយ អ្នកម្ចាស់ឡាននោះចាំសោភជា ប្រែន រូបបានទំនួនស្មារតីបីសោភ័ក្រ្តដាក់លើឡានយកទៅឯផ្ទះសំណាក់ នៅក្បែរនោះ ហើយធ្វើបដមព្យាបាល ។

ដល់សោភ័ក្រ្តបើចភែកឡើងឃើញអ្នកជួយសង្គ្រោះហើយ ក៏ស្ទុះ ឡើងបំរុងនឹងរត់ តែអ្នកនោះរបក់ដៃហាមឲ្យដេកទៅវិញ

"ប្អូនគេងទៅ កុំមាត់កអ្វីឯងអស់កំឡាំងណាស់" ។

រួចបានយកទឹកដោះគោមកបញ្ចុកឲ្យសោភ័ក្ត្រផឹក ពីរថ្ងៃកន្លងមក សោភ័ក្ត្រក៏មានកំឡាំងឡើងដើម្បីបាននិយាយកើត ទើបសួរទៅបុរសម្ចាស់ខ្ទមនិយាយតាំងពីរកោកអ្នកថា ...

"លោកបង ប្អូនស្មានជាគ្មានឃើញមុខហើយ នេះហេតុតែសំណាងយើងមាន ចុះក្មួយនិងអ្នកយើងបានរស់មានជីវិតដែរឬអ្វី ?

"ប្អូនអើយ យើងទាំងពីរបានបែកគ្នាទាំងអស់ ចាំបងនិយាយរឿងប្រាប់ឯងតាំងពីធ្លាយកប៉ាល់មក បងបានតោងក្តារមួយអណ្តែតហែលចូលដល់កោះមួយ មានមនុស្សព្រៃកុរការ តែនិយាយគ្នាស្តាប់ពុំបាន ពុំតថាយ៉ាងនេះ ក៏អ្នកស្រុកនោះគេបានយកបងទៅបញ្ចាំមួយចំនួន ៣ ខែ ថ្ងៃមួយមានកប៉ាល់ចូលទៅកោះនោះ បងបានជួនមកដល់តែបុះទូកមួយលើកមកទៀត បងដើរកាត់មកដល់កំពត បានអ្នកស្រុកម្នាក់មេត្តាយកបងទៅចិញ្ចឹម បងបានជួយធ្វើការគេស៊ី មានទឹកប្រាក់បំណុលជាច្រើន គេបំបែកហាងមួយឲ្យបងដាច់តែឯង ហើយបានទាំងលើកកូនក្រមុំឲ្យធ្វើជាប្រពន្ធផង បងបានសេចក្តីសុខជាបន្ទាប់មក តែតែងនឹកដល់ប្អូនមិនបានជានិច្ចដោយពុំដឹងជាបានរួចជីវិតឬយ៉ាងណា ដល់ទឹកអស់ទៅហើយ បងបានសរសេរសំបុត្រមួយប្រាប់ទៅស្នួលក្រុមយុត្តិធម៌យើងមក ក៏គេមិនឲ្យដោយគ្មានសេចក្តីអនុញ្ញាតពីបារាំង មួយទៀតក៏មិនដឹងជាអ្នកណាតាមរក

វក្យផង ដល់ជាប់ទៃមុននោះបងបានបំណេញច្រើន ស្រាប់តែមាន សំបុត្រមួយបញ្ជប់ពីស្រុកមក ដល់បងបើកមើលក៏បានសេចក្ដីថា ប៉ាខន អ្នកបានទទួលគេស្រង់រូបជីវិត ហើយបានសូន្យដើរហេយើងទាំងពីរនាក់ ជាច្រើនទៃ ក្រោយបង្អស់បានវិលទៅស្រុកវិញ ទើបបានដំណឹងថាបង មិនស្លាប់ បើជីងផុតគ្រោះ បងបង់ហានធនាំប្រពន្ធទៅស្រុក ប៉ាខន្សក កាន់តែជាសំណាស់ហើយឥឡូវនេះ ដោយសេចក្ដីទុក្ខបៀតបៀន យើញមុខបងទៅ គាត់ត្រេកអរណាស់ស្ទុះមកឱបបងយំបណ្ដើរផង បងនៅលេងបាន ៧ ថ្ងៃ គាត់ប្រែឲ្យបកកែឯងឯក្រុងភ្នំពេញក្រែងលោ ប្រែះ ទើបបងបានមកដល់ទីក្រុង សុំបសួរគេទៅគេថាឯងមិនដឹងជា ទៅណា បាត់បានបងទំកាត់គេទាល់តែជួប ឥឡូវត្រូវឯងនិយាយរឿង ឯងប្រាប់បងវិញ ៗ

សោភ័ក្រ្តបានកាយរឿងរបស់ខ្លួនសព្វគ្រប់ប្រាប់បង ហើយបង សោភ័ក្រ្តបបួលប្អូនវិលត្រឡប់ទៅស្រុកវិញនាថ្ងៃនោះ សោភ័ក្រ្តខំ គន់ចិត្តថា ឥឡូវអាត្មាអញបានជួបជុំបងប្អូនវិញ ខ្ញុះអ៊ីសម្បត្តិនឹងបាយ ពាយ សម្បត្តិកាយាវេទនសម្បត្តិណាជានៃត្រូលគ្នា ក៏មិនស្មើនឹងពាក់ កណ្ដាលសម្បត្តិពុកអញដែរ ឥឡូវខំគិតត្រឡប់វិលនៅស្រុកវិញ គេលថៃស្អកនេះ ។ ប្រសិនបើបានទៅទាន់ទៅជាមួយហ្ន៎ ដំណើរពីភ្នំពេញ ទៅស្រុកមុខជានឹងសប្បាយណាស់ ៗ

លុះដល់ក្រុងភ្នំពេញ ដើរលេងម្នាក់ឯងតាមផ្លូវ សោភ័ក្រ្តក៏ស្រាប់តែប្រទះនឹងកាហារ្យូ សួរឡើងថា

“សោភ័ក្រ្តឯងនេះទើបនឹងមកពីណា ខ្ញុំចាត់ឲ្យគេទៅរកកាសទំពក់ជីពុំឃើញ ឥឡូវគេត្រូវរៀបការថ្ងៃស្អែកហើយ ល្ងាចខ្ញុំលេងណាស់ចាំទៅផ្ទះសំមនិយាយគ្នាបានយូរ ឯងការណ៍គយកទាំងនេះទៅឲ្យណាជនេត្រផង ព្រោះនាងមិនស្រួលខ្លួន ។

រូបកាហារ្យក៏ដើរតទៅទៀតទៅ សោភ័ក្រ្តក៏មិនដឹងគិតដូចម្ដេចដែរ យកទាំងនោះ ដេញទៅឲ្យណាជនេត្រប្រាប់ថានឹងលានាងផង លុះសោភ័ក្រ្តចូលដល់បន្ទប់ខាងលើ ស្ងាត់មិនស្រួលមាននៅ បំណែកអ្នកផ្ទះទាំងមូលមិនស្រួលសប្បាយ អង្គុយមើលមុខគ្នា សោភ័ក្រ្តសាកសួរទៅបានសេចក្ដីថា នាងមិនស្រួលខ្លួនច្រើន ញាំយទំនមិនបាន គាត់តែស្ងួតខ្លួនពេលថ្ងៃ យប់គេពេទ្យមកមើលក៏មិនដឹងជារោគអ្វី ។ វេលានោះនាងកំពុងដេកនៅលើគ្រែ សោភ័ក្រ្តក៏សូមអនុញ្ញាតចូលទៅសួរជាសុខ ក៏ព្រមបើកឲ្យ ៖

“បងអញ្ជើញមកហើយឬអ្វី ?”

នាងនំក្រោកឡើងនិយាយសំឡេងញ័រៗ សោភ័ក្រ្តហាមមិនឲ្យនាងក្រោក រូបភាពញញើតកៅអីតូចមួយមកអង្គុយជិតគ្រែនាង កន្សែងខ្ទប់ពោះ គ្មានខនណានៅ ទើបអ្នកទាំងពីរនិយាយសាសងរកគ្នាទៅវិញទៅមកតាមចិត្ត ។

"ណុះនេត្រ អាចារ្យឲ្យខ្ញុំយកថ្នាំនេះមកជូន" ។

"ដាក់ត្រង់នេះចុះបង ថ្នាំនេះមិនអាចនឹងនៃអាការកើតប្អូនបានឡើយទេ" ។

"ចុះអ្នកសំឡាញ់មិនស្រួលត្រង់ណាខ្លះ?

នាងនៅស្ងៀមគ្រវីក្បាលជាទុក្ខ ។

"បើប្អូនមិនរំមើលខ្លួន ដូចម្ដេចនឹងបានស្រួលបាច់ ខានសុភាសិតលោកសំដែងទុកថា "អារោគ្យាបរមា លាភា" សេចក្ដីមិនមានរោគជាកំពូលនៃលាភទាំងពួង ទុកជាយើងមានសម្បត្តិស្ដុកស្ដម្ភយ៉ាងណាក៏ដោយ តែដេកលើគ្រែប្រាក់ ហើយយើងមានជម្ងឺឈឺកាយ នឹងគេសប្បាយដោយទ្រព្យនោះផងពុំបាន ពីព្រោះទឹកចិត្តមិនស្ងប់រម្ងាប់ អារម្មណ៍មិនស្រួលរលំតែនឹងឈឺចាប់ ដោយហេតុនេះហើយបានជាសេចក្ដីសះស្បើយបាត់រោគជាឡាភដ៏សំខាន់នៃសីលធម៌មួយជាគុណសម្បត្តិ ដ៏ប្រសើរបំផុតរបស់មនុស្សលោក ដូច្នេះកុំប្អូនប្រហែសខ្លួនឲ្យសោះអ្នកណា ព្រោះប្អូននឹងប្រើសិទ្ធិជាមេផ្ទះក្នុងពីរបីថ្ងៃទៀត ។

ដល់ត្រង់នេះ លោកគ្រូក៏អូលបំពង់កញ្ចើសំឡេងបន្តិច រួចឈប់មួយស្របក់ដើម្បីនឹងក្រោមខ្លួនសេចក្ដីកើតក្នុងចិត្តឲ្យស្ងាត់ចុះ នឹងមិត្តភក្ដិឲ្យចូលទៅក្នុងវិញ ដល់លោកគ្រូរៀបនិយាយតទៅទៀត នាងក៏បត់ដៃបាច់មួយៗ យ៉ាងអស់កំឡាំងរៀបនាងប្រែស្រយ៉ាប់ឡើងហើយយ៉ាងបាក់សតែចំណស់សំឡេងខ្ទប់ទាំងព្រាយ ។

"បងមិនប្រាថ្នាដំណើរប្អូនទេ ខ្លួនប្អូនសព្វថ្ងៃនេះបង្វែរចិត្តណាស់ ចំណែកកេរ្តិ៍របស់ប្អូនទុកជាកុមារពេញ ក៏រកថ្វីទុកបងបាត់ពុំបានដែរ មានតែព្រះកាឡប៉ុណ្ណោះដែលអាចកំចាត់បង់នូវកេរ្តិ៍ប្រពៃនេះបាន តែបងទុកជាយ៉ាងណាក៏ខ្ញុំមិននិយាយប្រាប់អ្នកណា អំពីហេតុដើមនៃកេរ្តិ៍របស់ខ្ញុំដែរ បើទុកជាប្អូនសៅហ្មងទៅក៏នៅតែសម្បកខ្លួនទេ... ។

"ប្អូន មានសុភាសិតមួយបទទៀត លោកសំដែងថា "អារម្មណ៍ដែលហួសហើយកុំនឹកនា" នឹងថាការដែលបានប្រព្រឹត្តកន្លងទៅ គប្បីទុកដូចជាយល់សប្តិ មិនគួរដំកល់ចិត្តសោកញយៗទេ ណ្ហើយប្អូន! កុំប្អូនចំបែងចិត្តអី បងដឹងច្បាស់សព្វគ្រប់ហើយ នេះគឺកម្មរបស់បងបានជាមានឧបសគ្គមកផ្តាច់សេចក្តីសង្ឃឹមគណ្ណា លេខ្លួនផ្លូវព្រះ មួយវិញទៀតខ្លួនបងមិនសមស័ក្តិនឹងប្អូនទេ ព្រោះពេលនេះបងសូមលាប្អូនទៅតាមយថាកម្មហើយ ពីរបីថ្ងៃមុនបង ដែលពេលទៅធ្វើការ គេបណ្តេញបងចោលហើយ ដោយហេតុដែលបងមិនបាននៅនាពេលអាពាហ៍ពិពាហ៍ បងសូមការពារខុសនេះនឹងផ្ញើបណ្តាសាចុះការដែលប៉ុនតែមួន សូមឲ្យប្អូនបានសេចក្តីសុខតទៅមុខ កុំឲ្យមានទោសកើតឡើងក្នុងគ្រួសាររបស់ប្អូន ញាតិមិត្តទាំងឡាយកើតចុះឡើងរកបាន ឥតលោះខានពេលណា ហើយសូមបងប្អូនឱ្យជួយថែរក្សាប្អូន កុំឲ្យមានគេនាក្បាលជើងទៀត ទៀតនៃកាយដ៏ល្អរបស់ប្អូន ចប់សេចក្តីត្រឹមហើយ បងសូមលាប្អូន

ម្ដងទៀត ណា គ្រានេះជាគ្រាក្រោយបំផុត ព្រោះបងពុំដែលជួនវិលមក ជួបមុខអូនទៀត" ។

សោភ័ក្រ្តបៀចខ្លួនក្រោកឡើង ណារុងទ្រហាត់ឲ្យនៅបន្ដិច ហើយទញ្ញាក់ទាយាក់ព្រួយថា ...

"បងអញ្ជើញទៅមែនឬ? អូនឃើញមុខបងជាគ្រាក្រោយបំផុតឬអ្វី?

"ពិតហើយអូន! យើងគង់តែបែកគ្នាទើបត្រូវ អូនកុំជាទុក្ខអី បងត្រូវតែបែកពីអូនទៅតាមមិនបានទេ បែរទៅដោយខ្លោចផ្សា" ។

ណារិនចាប់ដៃសោភ័ក្រ្តទាំងពីរ ទឹកភ្នែកក៏ហូរជោកមុខនាង...

"ចុះបងមិននាំអូនទៅផងទេឬ? ឲ្យអូននៅតែម្នាក់ឯងដូចម្ដេច?

"អូន! អូនកុំកាន់ចិត្តបែបនេះ ព្រោះជាការលើសលស់សេចក្ដីប៉ុនប៉ងប្រាថ្នាមាតាបិតារបស់អូន ព្រោះធម្មតាកូនគង់តែនៅក្នុងឱវាទរបស់មាតាបិតា គង់តែស្ដាប់ពាក្យលោក គង់តែលុះដោយដំបូន្មានរបស់លោក ព្រោះលោកប្រាថ្នាឲ្យអូនបានសេចក្ដីសុខ បើត្រង់ណាលោកពេញចិត្ត គង់យើងជាកូនបំពេញសទ្ធារបស់លោកដោយឥតប្រកែក ចំណែកបងៗ មានចិត្ត ត្រេកអរណាស់ដែលអូនបានសេចក្ដីសុខតទៅមុខ ហើយបងសូមប្រាថ្នានឹងអូនថា ចាប់ដើមពីថ្ងៃនេះតទៅ បងសុំនៅលីវគស់មួយជីវិត ព្រោះជីវិតរបស់បងនៅក្នុងកណ្ដាប់ដៃអូន ចាប់តាំងពីថ្ងៃដែលបងបានយល់មុខអូនមក" ។

ហ្គីយ៉ារូន! ធ្វើម្ដេចកូនរបស់បង បើកសាលាយើងមាន សូមឲ្យជាតិក្រោយបងបានជួបតែឪពុកអ្នក កុំឲ្យមានសេចក្ដីទទឹងទាស់ការអធ្យា-ស្រ័យដូចជាតិនេះឡើយ បងលាប្អូនសិនហើយណា ណុជនេត្រណា ៗ...

ណុជនេត្រស្រុះទឹកសោកក្រៃយំខ្សឹកខ្សួលមួយសន្ទុះ បានថយខ្លួនចេញ ។

"បង...បង...អញ្ជើញទៅឲ្យបានសុខសប្បាយ ចុះ..."

នាងប្រះខ្លួនលើគ្រែបិទមុខនឹងខ្នើយអណ្ដឺតអណ្ដកជាប្រែន នៅពេលនោះមានសំឡេងញឹសគុប ៗ លាន់ឮឡើង សោកក្រៃបែរមើលក្រោយ ក៏ឃើញមាតាបិតាណុជនេត្រឈរនៅមាត់ទ្វារ មានទឹកមុខស្រ-ពោនជោកទៅដោយទឹកភ្នែក នៅខាងក្រោយអ្នកទាំងពីរគឺអាចារ្យឈរក្រៀមក្រោះ; អ្នកទាំង ៣ នាក់បានឈរស្ដាប់ការសន្ទនានាងណុជនេត្រនិងសោកក្រៃពីដើមដល់ចប់ ហើយនឹកខ្លោចចិត្តដល់សំដីក្រមុំកំលោះទាំងពីរនោះពន់ពេក នឹកសង្វេគអនិច្ចាដល់ទាំងអ្នកដែលត្រូវនិរាសព្រាត់ទីស្រឡាញ់ពេញចិត្ត ។

ខណៈនោះអាចារ្យចូលដល់គ្រែនាង សួរនាងដោយសំឡេងញ័រថា "ណុជនេត្រមិនងាកមុខទទួលខ្ញុំផងទេឬ? នាងក៏បែរខ្លួនដោយភ្ញាក់ព្រើតស្រឡាំងកាំងស្មាគេទាំងញញឹមទទួលអាចារ្យ បំណែកសោកក្រៃក៏រៀបខ្លួននឹងថយចេញពីនោះ តែអាចារ្យទាញទុក ។

"កុំអាលទៅ លោកគ្រូ ការដែលខ្ញុំត្រូវនិយាយរកអ្នកពេលនេះ គឺត្រូវការឯងជាសាក្សី នៅពន្លឺយប់នៅនេះមួយរំពេចហើយ" អាចារ្យបែរមើលមុខណុជនេត្រវិញដែលទំព្រឹងស្រែកគន្លឺយដោយពិបាក អាចារ្យហាមមិនឲ្យនាងនិយាយទៀតនិយាយទៅកាន់នាងថា ! "ណុជនេត្រ ណុជនេត្រច្បាស់ជាមិនពេញចិត្តនឹងរូបសុខរបស់ខ្ញុំជាមួយនឹងខ្ញុំ ? ប្ដូរប្រាប់ឲ្យខ្ញុំបានដឹងផងលោះខ្ញុំនឹងអស់ពលចិត្តយូរតទៅទៀត" ណុជនេត្រញញាត់ទំរឿយតបថា "ទេបង ខ្ញុំមិនបានធុញទ្រាន់ដោយប្រការណាមួយទេឡើយ សុខចិត្តបង្អោនខ្លួនជាទាសីបំរើបាត់ជើងបងហើយ កុំបងសង្ស័យអ្វី ហេតុអ្វីដែលនាំឲ្យខ្ញុំខ្វល់អល់ចិត្តនេះក៏ហួសកន្លងទៅហើយ មិនពិតប្តីដែលលោកគ្រូនឹងអន្តរធានបាត់ពីជីវិតយើងទាំងពីរតាំងពីពេលនេះដរាបទៅ !

អាចារ្យត្រឹកក្បាលហើយឆ្លើយថា

"ណុជនេត្រ ខ្ញុំពេញចិត្តនឹងណុជនេត្រណាស់ហើយ ត្រង់ដែលមិនស្ញប់លះសេចក្តីសុខ ដើម្បីទិញតបស្នងសងគុណដល់ខ្ញុំ តែខ្ញុំកន់ចិត្តណាស់ដោយបានធ្វើសេចក្តីសុខរបស់អ្នកដទៃឲ្យសាបសូន្យពុះ ព្រោះមិនដឹងខ្លួនណុជនេត្រមិនប្រកាន់ទោសដល់ខ្ញុំផងពុំបាន ព្រោះខ្ញុំស្មានបតាំងពីបានស្គាល់ណុជនេត្រមក មានតែខ្ញុំហើយដែលមានសំណាងហោះណុជនេត្រថា "ប្អូន១" យាំងទន់ភ្លន់នោះ ពុំដឹងថាមានអ្នកដទៃអាចប្រែខ្លួនសិទ្ធិនេះ

បានដែរ ក្រោយពីព្រឹត្តិការណ៍នេះហួសទៅហើយ តាមតែនាងនេត្រមេត្តាអត់ទោសដល់ខ្ញុំផងចុះ ។

តែបើនាងនេត្រមិនពេញចិត្តនឹងខ្ញុំបែបនេះ ដូចម្ដេចក៏មិនប្រាប់ឲ្យខ្ញុំបានដឹង ស្ដាយណាស់មិនគួរប្រើសន្យាដល់គ្នាថានឹងមិនភ្លេចគ្នារហូតដល់ស្លាប់សោះ ឱលោកនេះជាទីជ្រកនៃសេចក្ដីមិនពិតហ្ន៎ !

ដល់ត្រង់នេះអាចារ្យក៏ឈប់មួយស្របក់ សំឡឹងទៅឆ្ងាយទឹកភ្នែកហូរធ្លាក់មកមួយរំពេច គឺទុក្ខជាដំបូងដែលអាចារ្យបានប្រទះ !

នាងនេត្រខ្ញុំសូមយកទឹកភ្នែក ដែលហូរមកលើមុខខ្ញុំជាគ្រាដំបូងបង្អស់ជាសាក្សី ខ្ញុំនឹងសំដែងសេចក្ដីពិតនាគ្រានេះ ខ្លួនខ្ញុំបានហ្វឹកហ្វឺនចិត្តឲ្យផូរផង់តាំងពីតូចដរាបរៀនមក មិនដែលចំពាក់ចំពែកអ្នកឯណា ដោយតាយកចិត្តដល់ម្ដងទៅឡើយ មកម្ដងនេះ បែរជាប្រព្រឹត្តខុសគន្លងផ្លូវធម៌ទៅវិញ គួរឲ្យសោកស្ដាយក្ដៅក្រហាយលើសលប់ ខ្ញុំប្រាសកម្សិបចិត្តហើយថា បើខ្ញុំនៅតែប្រកាន់ខាងនេះនោះ មុខជាបានសំរេចផ្លូវសេចក្ដីប្រាថ្នាពុំខាន ហើយនាងនេត្រក៏យល់ព្រមដូច្នោះដែរ មិនមែនឬ !

“ពិតហើយបង.....” ។

ប្អូន អាពាហ៍ពិពាហ៍មានដំរិះច្រើន គឺជាអ្នកតាំងពីរូបនោះ គេនឹងមានសេចក្ដីស្នេហាគ្នាទៅវិញទៅមក ដើម្បីនឹងឆ្លងកាត់សមុទ្រជីវិតទៅដោយសុខ ។ ព្រោះមានតាទីជំនឿតែកក្ដី ទាំងក្រោយឲ្យបាន

ចំរើនឡើងជាកាលស្រុកដីប្រសើរសំបូរប្រទេស   កាលនោះប្រាសាទ
សេចក្តីស្នេហាហើយ  នឹងឲ្យឈ្មោះថាតាពាហ៍ពិពាហ៍ណាចំបាន  ណា
មួយចិត្តគំនិតមិនត្រូវញ៉ាំងលួចតែមួយផង   គួរឲ្យហៅថា   សេចក្តី
សេចក្តីនៃផងវឹងចិត្តវិញទើបសួរ   ហេតុនេះខ្ញុំសូមផ្តាំទូនបេញកំពិសារជាចំនុច
ព្រោះមានសេចក្តីប្រាថ្នាតែមួយយ៉ាងឲ្យណាផងនេះក្រោមនេះសេចក្តីសុខតែ
ប៉ុណ្ណោះ   ទឹកភ្នែកដែលហូរមកអស់ញាំញីម៉ែញនេះមិនផុតប្រយោជន៍ទេ
ព្រោះខ្ញុំនឹងប្រព្រឹត្តជាចំនួនជួបប្រតិស្នេហ៍ផ្ទាត់ឲ្យតែវេលាអស់តាំងពី។" ។

ភាតារៀចំពរណាផងនេះព្រមប្រគល់ឲ្យសោកក្រៀម   អស់តាំងពីកើតស្ទើយ
ក្រុមផ្ទុំចុះដុតដើមកាតារៀ   ភាតារៀកបួងសួងថា៖

"សូមគុណព្រះគង្គ្រីយជួយឲ្យទ្រង់ស្រឡាញ់   មួយគូនេះផង
អស់ទោស"   ។

ចប់រឿងកំពូលស្នេហាចប់តែប៉ុណ្ណេះ ។

---

## ពាក្យកែតម្រូវ

រឿងកំពូលស្នេហា   វគ្គទី ១ ក្នុងសៀវភៅកម្ពុជសុរិយា លេខ ១ ខែ
ឆ្នាំនិរោធ ១៩៦៦ ទំព័រ ៩ បន្ទាត់ ១២-១៣ ត្រង់ពាក្យថា "យូរបន្តិច
លេចគេហារៀប្រៀនបើកថយឆ្ពោះមកដល់ទីនោះហើយចាញ់ចំរើងដូរហៅ
សោកក្រៀមឲ្យឡើងជិះ   រួចបើកចេញពីទីនោះទៅមួយរំពេច"  ត្រូវតែថា

ផ្លូវវិញ៖ "បក្សិបមង ឃ្លានបាយខ្លាំងណាស់ សូមសប់កខ្ញុំផង លោកគ្រូក៏ឈរមើលនិងផ្លូវចុះទៅលើផែនដី, ចួនជាពេលនោះមានរថយន្តមកផល់ទីនោះក៏ឈប់, អ្នកម្ចាស់ឡានចុះមកព្យាបាលលោកគ្រូទាល់តែបានដឹងខ្លួន; លុះបើដឹងរឿងកុមារកំសត់សព្វគ្រប់ហើយ អ្នកម្ចាស់ឡានក៏និយាយប្រាប់ថា:

"ខ្លួនខ្ញុំនេះធ្វើលេខានុការនៅក្រុងភ្នំពេញ អ្នកផងគេតែងហៅខ្ញុំថាអាចារ្យ ១ ព្រមគ្នា ឯងកុំបារម្ភ ចាំខ្ញុំជួយទំនុកបំរុង"

ថាហើយក៏នាំលោកគ្រូឡើងជិះឡានបើកចេញពីទីនោះទៅ ។

---

## រឿងអន្តរាគតក្នុងសតវត្សរ៍ទី ១៦-១៧

## ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម

ប្រែនិងសង្កេតចេញពីសៀវភៅ Religieux et Pèlerins en Terre d'Asie របស់លោក Victor Goloubew សមាជិកសាលាបារាំងសែសចុងបូព៌ាប្រទេស ។

(តទៅ)

---

នូវតែបន្ថែមឈ្មោះលោក ១ រូបទៀតជាគំរប់បីរូប, គឺលោកគ្រូ Zonge de Mota ដែលគេស្គាល់ជាជាងគេក្នុងនោះ លោកជាជាតិបា-កិនថែមសត់ព្រោះតាមការពិត គេហៅឈ្មោះលោកថា Grégoire de la Mothe ។ ដោយហេតុនោះ គេដឹងថាលោកគ្រូ Mothe ចេញអំពីសំណាក់វត្ត Saint Dominique នៅស្រុកម៉ាឡាកា កាលពីឆ្នាំ ១៥៨៤-១៥៩០ ដើម្បីចូលមកក្នុងស្រុកខ្មែរប្រដៅសាសនាព្រះយេស៊ូ ។ លោកនេះឯងជាអ្នករួមដំណើរដើរផ្សាយជាមួយនឹងលោក Louis de Fonseca ។ ចុះជាក្រោយដែលញ្ញាក់ជាពិតប្រាកដ ក៏ប្រហែលប្រាកដជាលោកគ្រូ ដែលជាមុន មានឱកាសចូលទៅមើលអង្គរ ហើយនៅក្នុងនោះ ដូចជាលោកគ្រូទាំងពីររូបនោះដែរ ។

— ៤ —

សង្ឃឹមខ្មែរ យើងមើល; តើអង្គរតបណ្ដាលគេហៅឯណា តាមវិជ្ជាសាស្ត្រក្នុងស្រុកដែលបាត់ឲ្យមានឡើង ក្នុងសម័យដែលពួកខ្មែរគ្រប់

ប៉ុន្តែមកជួបប្រទះនឹងវិក្រឹតការរបស់ខ្លួនវិញនោះ ។ ក្នុងថ្ងៃមួយក្នុងប្រាសាទអង្គរវត្ត មានផ្ទាំងតារកបួនស្នួនចំនួន ៤០ ផ្ទាំង ដែលគេបានធ្លាក់លើសសរថ្មផ្សេងៗ នោះលោកកៅថេនកាយម៉ូញ៉ា និងអ្នកវិតពង្សា-វតារឯទៀតៗនៃស្រុកខ្មែរ បានដាក់ទុកសេចក្ដីទាំងនោះនៅក្នុងចំណោមសេចក្ដីតារកជាំនថ្មី ពីព្រោះសិលាចារឹកទាំងនោះ កើតក្រោយការកសាងប្រាសាទជាច្រើនសតវត្សរ៍ ។ សិលាចារឹកដែលចាស់ជាងបំផុតនោះ កើតឡើងក្នុងឆ្នាំ ១៥២៣ ។ សិលាចារឹកដែលកើតជាបន្ទាប់តមកត្រូវទៅលើឆ្នាំ ១៥៦៦ ។ សិលាចារឹកនោះបានរំលឹកផលពិធីបុណ្យធ្វើព្រះវិហារ ១ ដែលគេទើបតែចាប់កសាងឡើងក្នុងឆ្នាំ ១៥៥៥ ។ យើងត្រូវចាំកំណត់សករាជនេះទុកចុះ ពីព្រោះសករាជនេះនាំឲ្យយើងកែប្រែបានខ្លះ ចំពោះសេចក្ដីការសំគាល់របស់ពួកអ្នកដំណើរប្រទេសក្រៅ តាមពាក្យដែលថា អង្គរលើបនៃទីនេះកើតមានប្រាកដឡើងក្នុងពង្សាវតារខ្មែរក្នុងឆ្នាំ ១៥៧០ ទេ គឺរាវពេលរយៈ ១៥ ឆ្នាំតមកទៀត ។

មានសិលាចារឹកពីរ នៅអង្គរវត្តដែលធ្វើឲ្យសេចក្ដីស្រងួត នោះនាំឲ្យយើងដឹងហេតុកេតប្រវត្តិការណ៍កំពូលរុងរឿង ទាំងខាងអាណាចក្រទាំងខាងពុទ្ធសាសនានៅស្រុកខ្មែរ ។ ក្នុងសេចក្ដីទាំងពីរផ្នែកនោះសេចក្ដីទី ១ ដែលរៀបរាងដោយហ្លួងហែ មាននិយាយអំពីព្រះករុ-ណា ១ អង្គ ដែលទ្រង់បានធ្វើដំណើរយាងទៅនមស្ការអង្គរ ។ ល្បះ

ព្រះអង្គបានបួសស្នងគុណដល់ព្រះពុទ្ធ ដែលទ្រង់ទុកជាម្ចាស់-ជាទីពឹង ជាម្លប់ត្រជាក់ត្រជុំរបស់ព្រះអង្គហើយ ទើបព្រះករុណាជនពីជាតសព្វព្រះថ្វា ទ្រង់ចុះប្រកាសថ្ងៃទីអភិការកុសល ១ ដែលទ្រង់បានធ្វើនៅវេលាដែលព្រះអង្គមានព្រះជន្មនៅឡើយ; ក្នុងឆ្នាំ១៩៤៧ នៃស្វយោគ នោះព្រះអង្គនឹងឃើញការដែលព្រះមហាក្សត្រជាព្រះបរមបុត្រ បានធ្វើការផ្នួសផុលព្រះវិហារទាំងឡាយនៅអង្គរវត្ត ៗ ការដែលព្រះមហាក្សត្រជាព្រះបរមបុត្រទ្រង់ធ្វើដូច្នោះ ព្រះវររាជមាតាមានព្រះទ័យត្រេកអរសោមនស្សក្រៃ ៗ ព្រះអង្គមានព្រះហឫទ័យប្រកបដោយសេចក្ដីសន្ដោសស្ដុកស្ដម្ភ ទ្រង់ពិ-ចារណាឃើញការប្រែប្រួលមិនទៀងទាត់នៃពិភពលោកនេះ ទើបព្រះអង្គកាត់ព្រះកេសាបួសជាព្រះកត្តី ៗ

បុណ្យការផ្នួសផុលជាថ្មីនេះក៏ ធ្វើឲ្យព្រះវររាជជននីបានសម្រេចតាមបំណងដួងចិត្តម្ដង៖ ។ ដើម្បីឲ្យដឹងជាក់នោះ ទាល់តែគេសរសើរនៅមើលសេចក្ដីទៅ ដែលកើតឡើងក្នុងឆ្នាំ ១៩៤៩ ៗ ក្នុងសេចក្ដីនោះគេមើលឃើញថា ព្រះមហាក្សត្រត្រិតរិះសម្បត្តិ "ទ្រង់បានទតឃើញច្បាស់ នូវសេចក្ដីចំរើននៃព្រះសាសនា" ទើបទ្រង់បានបាច់ធ្វើការតាមចំនងដែលលោមធ្វើបាននៅអង្គរវត្ត ៗ ទ្រង់បានឲ្យយកបន្ទើងទៅផ្នួសផុលកំពូលប្រាសាទទាំង ៤ ដែលបាក់បែកខូចបន្តិចទៅដល់ពាក់កណ្ដាលហើយ ហើយយកមាសទៅចងស្រោបកំពូលទាំងឡាយ គង់គង់ក៏

សព្រោបដាក់ព្រះសារីរធាតុ ហើយទ្រង់ធ្វើពិធីបុណ្យយ៉ាងរុងរឿង ទើបទ្រង់ឧទ្ទិសថ្វាយព្រះរាជកុសលឲ្យបានសម្រេចដល់ព្រះវិញ្ញាណក្ខន្ធ របស់ព្រះមហាក្សត្រ ជាព្រះវររាជបិតាដែលទ្រង់ទិវង្គតទៅ និងពួក ព្រះរាជបុព្វបុរសរបស់ព្រះអង្គ ។

សេចក្ដីសំខាន់នៃពិធីបុណ្យនេះ ជាគ្រឿងបញ្ជាក់ឲ្យឃើញច្បាស់ ថា ក្រោយសម័យដែលក្តេចក្តាំងបាក់បង់ទៅដោយយូរអង្វែងនោះ ក្រៅទុក មន្ទីរវត្តជារបស់ធំទូលាយបំផុតហើយថ្កុំថ្កើនបំផុត នៅក្នុងចំណោមប្រា- សាទខ្មែរទាំងឡាយ ហើយមានជីវិតរស់ឡើងវិញយ៉ាងអកៈធឹក ហាក់ដូច ជាបំភ្លឺឲ្យឃើញសេចក្ដីថ្កុំថ្កើនថ្មីៗ ដែលកន្លងមកហើយ ។ ប៉ុន្តែ សង្ឃដែលគេគោរពបូជា ដែលគេបានកប់តាំងពីពេលនោះមកមិន មែនជារូបអង្គព្រះមហាក្សត្រដែលទិវង្គតទៅ ដែលគេធ្លាប់ទុកដូចជា ទេវតា ដោយមានទ្រង់ទ្រាយជាព្រះវិស្ណុ ដែលជាព្រះបែនការ ១ អង្គ កន្លងចំនួន ១០ អង្គនោះទេ ។ តាំងពីពេលព្រះមហាក្សត្រទាំងឡាយ នៅអង្គរ បានបោះបង់ចោលក្រុងរបស់ទ្រង់ទៅ ស្រុកខ្មែរទាំងមូលក៏បាន ផ្លាស់ចិត្តគំនិត បែរមកកាន់ព្រះពុទ្ធសាសនាវិញ ។ ឯវិជ្ជាចំពោះ ខាងសាសនាហិណ្ឌូ ដែលពួកព្រាហ្មណ៍បានធ្លាប់បង្ហាត់បង្រៀនមកនោះ ក៏ផ្លាស់ប្រែបែរមកកាន់លទ្ធិហីនយានជាជំនួសវិញ ។ លទ្ធិហីនយាននេះ ជាលទ្ធិដែលបានទេសនាទូន្មានដោយពួកភិក្ខុដែលកោរក្បាល ស្លៀក

កាត់សក់ពាក់ពណ៌លឿង ហើយជាពួកដែលនិយមប្រើភាសាមួយប្រហែលៗ គ្នានឹងភាសាសំស្ក្រឹត គឺភាសាបាលី ដើម្បីផ្សាយលទ្ធិសាសនារបស់ខ្លួន ។ ពួកនេះ ផ្តុំគ្នាជាគណៈសង្ឃមានចំនួនច្រើន ជាពួកដែលបានដឹកនាំសីលធម៌ខាងសាសនា និងរបៀបប្រផាគមជាន់ខ្ពង់ខ្ពស់ មកផ្សាយក្នុងស្រុកខ្មែរបានសម្រេច ។ ពាក្យខ្លួនប្រៀនប្រដៅរបស់ពួកព្រះសង្ឃនេះ ផ្ទុយគ្នានឹងរបស់ពួកព្រាហ្មណ៍ គឺមិនបានបង្អាក់បង្វៀនចំពោះមនុស្សដែលជាពួកមន្ត្រីជាន់ខ្ពស់ ឬពួកអ្នកមានបុណ្យសក្តិធំនិងសំណាក់ទេ. គឺបង្ហាត់បង្រៀនទៅដល់ប្រជាជនទូទៅទាំងអស់ ទៅដល់ជនជាន់ទាបបំផុត ក៏ដូចជាពួកអ្នកមានបុណ្យនិងអ្នកមានសម្បត្តិដែរ មិនយូរប៉ុន្មានក៏បានបង្កើតជាគណៈសង្ឃ ដ៏មានឥទ្ធិពលមួយនៅស្រុកខ្មែរ បរុតែចាំជួយទ្រទ្រង់ព្រះរាជវង្ស ដែលសោយរាជសម្បត្តិ កាលបើមានរឿងហេតុអ្វីឡើង ប៉ុន្តែក្សត្រិយ៍វង្សនោះត្រូវគោរពដល់លទ្ធិសាសនា និងច្បាប់វិន័យរបស់សាសនា ។ [illegible]

អំពីការប្រែប្រួលគ្នារវាងព្រះមហាក្សត្រខ្មែរ និងគណៈសង្ឃពុទ្ធសាសនានៅអង្គរវត្តនោះ មានសិលាចារឹកក្នុងឆ្នាំ ១៥៧៩ នាំឲ្យគេឃើញដើមហេតុជាប្រយោជន៍ដល់យើងជាច្រើន ។ សិលាចារឹកនោះថា «សម្តេចព្រះករុណាស្រីក្សត្រិយ៍អគ្គមហាសិរី ព្រោះតែវណ៌ទ្រង់ផ្ទះពីស្រីធម្មរាជបវិត្រ ទ្រង់គតិនោះ សម្តេចព្រះមហាឧបាសកមហាពេជ្របវិត្រ

មានព្រះបរិតចិន្តាប្រាថ្នាចំពោះព្រះរាជបុត្រនេះ ទោះប្រុសក្តីទោះស្រី ក៏ទ្រង់ព្រះរាជអធិដ្ឋានថ្វាយ ផា១ ធូសេក១ ហ៊ុសិកា១ បង្គាប់សម្តេចព្រះមហាស្រីរត្នត្រៃបរមបពិត្រ សូមសំណាក់ក្តីពោះព្រះសាសនា ព្រះតថាគតហោង កុំបីចាកលែងព្រះសាសនាឡើយ ទោះព្រះរាជបុត្របុរស(បុត្រប្រុស) ក៏ព្រះរាជអធិដ្ឋានថ្វាយជាពុទ្ធបុត្រចំណាក់ព្រះមហា-ស្រីរត្នត្រៃបរមបពិត្រជាប្រធាននៃព្រះអង្គ លុះបានបួសសំណាក់ព្រះសាសនាហោង លុះកាលណាលាផ្នួសបព្វជ្ជាកម្មវិលវិញមកសូមបានតែងព្រះរាជប្រវេណីមហាក្សត្រវិញ សូមសំណាក់ក្តីពោះព្រះមហាស្រីរត្នត្រៃបរមបពិត្រជាប្រធាន ចំណាក់នៃព្រះរាជបុត្រនេះហោង[១]" ។

សេចក្តីបួងសួងរបស់ព្រះអគ្គមហេសីក្សត្រនេះ ក៏បានសម្រេចសមបំណងគ្រប់យ៉ាង ។ លុះដល់កាលណាព្រះនាងប្រសូតព្រះរាជកុមារមក ព្រះមហាក្សត្រជាព្រះរាជស្វាមី ទ្រង់តាំងឡើងជាវឌ្ឍយាទ (ស្នងត្រកូល) នៃរាជបល្ល័ង្ក នៅចំពោះមុខព្រះសង្ឃអគ្គវត្ត ដែលបានទទួលទ្រង់ជាឧបាសក ។ ខ្ញុំមិនបាននិយាយពីព្រះរាជពិធីថ្វាយព្រះពរជ័យ ទឹកពិធីពលីការបួងសួងផលបុព្វបុរស ដែលគេបានធ្វើឡើងក្នុងឱកាសនោះទេ ប៉ុន្តែគួរនិយាយយ៉ាងខ្លីអំពីការបួងសួង ដែលយើង

---

១ នេះជាសេចក្តីក្នុងសិលាចារឹក ១ អង្វើ យើងបានស្រង់ចេញមកអំពីសៀវភៅសិលាចារឹកភាគរង្គ ត្រង់ទំព័រ ៦ នៃលំពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពផ្សាយ ព្រោះអានទំនងតាមតែក្តីត្រឹមត្រូវនិងសេចក្តីប្រែជាភាសាបារាំង ។

ហើយនឹងស្រទាប់ពាក្យតាមកាលមួយអន្លើ ៗ បើគ្រាន់តែក្រឡេកមើលភ្លាម នោះឃើញមានតែរបៀបពាក្យសាំញ៉ាំ ដែលគេតែងប្រើទៅតាមកាលសម័យ ហើយសំពាក្យដែលប្រើប្រយោគសេចក្ដីតាមរបៀបពុទ្ធសាសនាអក្សរសម័យនោះ ៗ ក្រុះតែពិនិត្យមើលរបៀបហាក់បក់ត្រង់សេចក្ដីខ្លះទៅ ហើយគេឃើលថាជាពាក្យបរិនិយាយព្រំដែល ៗ មានទំនងហាក់ដូចជាមានគំនិតគិតដល់រឿងគ្រោះថ្នាក់អន្តរាយ...., ដូចជាពាក្យថា "សូមទេពតាផងគ្រប់ដែនលំនៅនេះសម្ដេចព្រះមហាក្សត្រ មហារាជបពិត្រ នូវសម្ដេចព្រះរាជទេពីបពិត្រទាំងពីរព្រះអង្គ នូវព្រះរាជបុត្រ នូវសម្ដេចព្រះរាជមាតាបពិត្រ នូវស្រីស្រីឆ្នាបរិវារ នូវរាជគ្រូព្រាហ្មណ៍អាចារ្យ មន្ត្រីមុខបុគ្គលក្រមការសត្វប្រក្ខ័ត ករុណាទាំងនូវរាជបរិស័ទផង សូមឲ្យរួចផុតផ្លុតសព្វទុក្ខ សព្វសោក សព្វរោគ សព្វភ័យ សព្វចង្រៃ សព្វឧបទ្រពអន្តរាយផងផ្សេងៗ នានាប្រការ សូមចំរើនសព្វសុខសួស្ដីការ ពិពិទ្ធមួយសារគស់កាលដើលនិទាន ឈ្មោះអស់សត្រូវផង សម្លាញ់ ពោះបង្កាន់បជសត្រូវផង (មកពី) សព្វទិសទី មានចិត្តគិតមករៀតបៀនកម្ពុជប្រទេសនេះ មកបំពានព្រះសាសនាព្រះមហាសារិកធាតុគុះ នៅក្នុងសាណាទិសទ្ធិនេះ សូមទេវតាផងបង្អុំចិត្តសត្រូវនោះ កុំបីឲ្យមកបៀតបៀនកម្ពុជប្រទេសនេះ នូវព្រះសាសនាព្រះមហាសារិកធាតុឡើយ[1]" ៗ

---

១ នេះជាសេចក្ដីខាងចុងក្នុងសិលាចារឹកដែលរកឃើញនៅគុះឯក យើងស្រង់ពាក្យមកពីសិលាចារឹក នគរវត្តត្រង់ទំព័រ ១១-២ ។

ខុតជាសេចក្តីចារឹក មិនបានសរសេរប្រាប់សិរីហើរនៅក្នុងសៀវ ប៉ុន្តែរឿងនេះប្រហែលជាជាប់ទាក់ទងទៅនឹងសារចម្បាំងថ្មី កេរ្តិ៍ខ្មែរ នឹងប្រទេសផិតការទុះឯង, តាមដោយពិត បើសើរមើលពង្សាវតារ ថៃ នឹងឃើញថាក្សត្រប្រទេសសៀម ព្រះនាមព្រះណារេត (នរេសូរ៍) ទ្រង់លើកទ័ពចូលមកច្បាំងលុកលុយស្រុកខ្មែរ ក្នុងឆ្នាំ ១៥៨៣ ដែល មានចំនួនទ័ពប្រកបដោយ "ចំនួនពលមនុស្ស ១០០, ០០០ ដំរី ៨០០ សេះ ១៨៥០" ក្សត្រអង្គនេះ វាយយកបានបន្ទាយដំបង ព្រោះសាក់ ចម្បាំង ជាធំនោះ ពួកកងទ័ពខ្មែរច្បាំងទប់ទល់យ៉ាងមុឺងម៉ាត់ហើយដេញវាយទៅ វិញ តែលុះបួនឆ្នាំក្រោយ ក្សត្រអង្គនោះត្រឡប់លើកទ័ពចូលមកច្បាំង ទៀត មានចំនួនទ័ពច្រើនសំបើមលើសមុនទៅទៀត ។ ចម្បាំងលើក ទី ២ នេះ ជាសារបញ្ចប់នៃការបរាជ័យរបស់ក្រុងលង្វែក នៅឆ្នាំ ១៥៨៧ ។ ការបរាជ័យជាធំនោះ នាំឲ្យមានគ្រោះថ្នាក់ធ្លាក់ដល់ស្រុកខ្មែរជាសំបើម ។ ព្រះមហាក្សត្រនឹងព្រះរាជវង្សានុវង្ស ក៏ត្រូវចាប់ខ្លួនធ្វើជាឈ្លើយហើយ ត្រូវនាំទេសចរទៅ ។ ផែនដីមួយភាគធំរបស់ស្រុកខ្មែរ ក៏ត្រូវកាត់ផ្តាច់ ទៅជារបស់សៀម ហើយបន្ទាប់គំពីហេតុភេទគ្រោះថ្នាក់អន្តរាយទាំង នោះ ដែលធ្លាក់ស្រោចមកលើស្រុកខ្មែរ គឺកើតចម្បាំងក្នុងស្រុក កើត ចលាចល កើតទុព្ភិក្ខភ័យ រោគភ័យ អគ្គិភ័យ មានសត្រូវគ្រុះ ៗ ក្រៅពីមហាភ័យធ្ងន់ៗទាំងនេះ នៅមានកិច្ចការប្រទេសក្រៅចូលមក

ព្រៀតដែកក្នុងស្រុកខ្មែរថែមទៀតផង តាំងនេះមិនមែនតែឲ្យមានព្រោះ ជាក់ចំពោះស្រុកខ្មែរប៉ុណ្ណោះទេ គឺនាំឲ្យកើតកំពុលជាខ្លាំងដល់ប្រទេស ឥណ្ឌូស៊ីនទាំងមូលផង ក្នុងវេលាគ្រានោះ ប្រសិនបើកិច្ចការទាំងឡាយ· កលរបស់ Diego Belloso, និង Gallinato ព្រមទាំងអ្នកដើរទេសជាតិ អេស្ប៉ាញឯទៀត ដែលទទួលបៀវត្សរ៍របស់ភ្នាល់ម៉ានិល ធ្វើការបានសម្រេចសមដូចបំណង ។

— ៥ —

បើទុកជាស្រុកខ្មែរ មានសេចក្ដីវៀវក្រោយសាបសូន្យយ៉ាងធំដូចម្ដេចក៏ដោយ ក្នុងសម័យដែលមានចម្បាំងនឹងមានបលាបលនោះ នោះហាក់ដូចជាមិនមានប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ប្រាសាទអង្គរវត្ត ដែលជាកន្លែងបូជនីយដ្ឋាននោះឡើយ ។ មានសេចក្ដីបរិកតាំងនឿដែលកើតឡើងក្នុងសម័យនោះ ដោយមានចេញឈ្មោះរបស់មន្ត្រីជាន់ខ្ពស់ម្នាក់ក្នុងពួកសំណាក់ ឈ្មោះអតិយោគ ជាអ្នកមានសទ្ធាជ្រះថ្លាចំពោះប្រាសាទនេះ ដោយបានកសាងព្រះពុទ្ធ, ចេតិយ, និងបដិមាតូចៗធ្វើពីសំរឹទ្ធ, ឈើ, ព្រះសារីរិកធាតុ ខាសនិងប្រាក់, កួស, ស្រីអង្គម្ល ស្លា . . . ។ សេចក្ដីបរិកតាំងនេះ កើតឡើងក្នុងឆ្នាំ ១៥៩៩. ។ បរិកនេះប្រហែលជាកើតក្រោយ ២០ ឆ្នាំ គឺក្រោយបារិកដែលយើងបាន

កោលមករួចហើយ ដែលជាចរិតមានទំយ៉ាយពីការប្រជុំនឹងធ្វើពិធីបុណ្យជាទុច្ចរិត។ នៅត្រង់កន្លែងដែលព្រះរាជបុត្រប្រសូតនិងទ្រង់ព្រះផ្នួសក្នុងបរិវេណក្រុងហោទគ្គវត្តនោះឯង ។ ហើយសិលាចារឹកទាំងពីរនេះមានសេចក្ដីបញ្ចប់ដោយពាក្យបួងសួងដល់ពួកទេវតា ដែលថែរក្សាព្រះធរណីថា "សូមឲ្យទេវតាទាំងឡាយ បណ្ដេញកំចាត់ពួកសត្រូវនៃព្រះធម៌ ព្រមទាំងពួកសត្រូវរបស់ព្រះមហាក្សត្រ ដែលលើកមកវាយប្រទេសកម្ពុជា; សូមឲ្យបណ្ដារាស្ត្រជាតិខ្មែរ ប្រកបដោយសេចក្ដីសុខសប្បាយជានិច្ច" ។ ក្នុងពាក្យបួងសួងខាងក្រោយនេះ នាំឲ្យគេស្មានថា ប្រហែលជាមានសង្គ្រាមមួយថ្មីកើតឡើង ដោយមានប្រាជ្ញយ៉ាងខ្លាំងចង់ឃើញស្រុកទេសដែលធ្លាក់ចែកខ្ចូចខ្ចីដោយបម្បាំង គួរឲ្យអាម៉ាសមុខនោះ ត្រឡប់បានសេចក្ដីចំរើនឡើងវិញ ។ តែមិនមានហេតុឲ្យឃើញជឿថា ពួកទេវតាឬអ្នកតាថែរក្សាស្រុក ដែលលោកអភ័យពរជាបំរើរបស់នគរខ្មែរ បាននាំស្រុកបួងសួងបន់ស្រន់ឲ្យជួយនោះ បានទទួលជំនឿ ឬធ្វើឲ្យសម្រេចតាមពាក្យបន់ស្រន់ឡើយ ។ មិនប៉ុន្តែប៉ុណ្ណោះ ក្រោយដែលមានសេចក្ដីស្ងប់ស្ងាត់យ៉ាងខ្លី ប្រទេសកម្ពុជាក៏ត្រឡប់ត្រូវប្រទេសសៀមលុកលុយម្ដងទៀត ដែលទាំងខាងក្នុងស្រុកក៏មានកើតក្បត់ និងកើតចលាចលកាប់សម្លាប់គ្នាវឹកវរ ។

ក្នុងចំណោមសិលាចារឹកបន់ស្រន់នៅប្រាសាទអង្គរវត្ត នោះពួកសិលាចារឹកដែលកើតឡើងក្នុងសតវត្សរ៍ទី ១៧ មានចំនួនច្រើនបំផុត ។ តាមរឿងរ៉ាវដែលបញ្ជាក់ឲ្យយើងបានដឹងនោះ មានទំនងដូចជាក្នុងសតវត្សរ៍ផុតៗនេះដែរ គឺថាប្រាសាទអង្គរវត្តជាកន្លែងបូជនីយដ្ឋាន ជាទីគោរពបូជាការនៃពុទ្ធសាសនា ជាទីមានអ្នកដំណើរដើរមកហូរហែកប់ដោយចំនួនពាន់ៗ ដើម្បីធ្វើចិត្តគំនិតរបស់គេឲ្យបានស្ងប់ស្ងាប់ និងប្រាថ្នាបុណ្យផលទៅអនាគតជាតិ និងឲ្យបានរួចរបូតអំពីវេទនា ។ មនុស្សគ្រប់ដំណើរទាំងនោះនាំគ្នាមកអំពីគ្រប់ទិសទាំងជិតទាំងឆ្ងាយ ព្រមទាំងប្រក្រុមគ្រួសារមានខ្ញុំកំដរភោគទៅផង សុទ្ធតែមានដៃកាន់គ្រឿងសក្ការបូជា ។ ទីសំណាក់របស់ជនទាំងនោះ ច្រើនតែនៅក្នុងថែវបរិវេណប្រាសាទនៅកណ្ដាលពួកលោកសង្ឃដែលថែរក្សា ទើបជាការបើកឱកាសឲ្យដោះលែងខ្ញុំកំដរបាព្រោះ ជាកំពើកុសលមួយដោយឡែក ដែលអ្នកប្រព្រឹត្តអំពើដូច្នោះ តែងបានទៅកើតនៅស្ថានទេវលោក ។

ទុកជាសិលាចារឹកទាំងឡាយមិនបានពោលដល់សោះ ក៏គង់តែប្រហែលជាអង្គរវត្ត មានក្សត្រស្ដេចចេញទៅធ្វើទស្សនកិច្ចជាច្រើនដង ដើម្បីគោរពសក្ការបូជនីយដ្ឋាន នៅក្នុងរវាងសតវត្សរ៍ទី ១៧ ។ មានព្រះរាជទស្សនកិច្ចមួយដែលមានសេចក្ដីដំណាលទុកដោយពិស្ដារ នៅក្នុង

